អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២

# សេចក្តីជូនដំណឹង
# របស់ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អ.វ.ត.ក
# ទាក់ទងនឹងបញ្ហាកង្វះសាច់ប្រាក់សម្រាប់បើកប្រាក់ខែនៅខែធ្នូ ឆ្នាំ២០១២
# និងស្ថានភាពថវិកាឆ្នាំ២០១៣

កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១២ ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាល ស្តីទីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានជួបប្រជុំជាមួយបុគ្គលិកជាតិទាំងអស់នៃ អ.វ.ត.ក ដើម្បីពន្យល់ពីការវិវត្តន៍នៃសាលាក្តី និងជាពិសេសអំពីបញ្ហាប្រឈមកង្វះសាច់ប្រាក់សម្រាប់បើកប្រាក់ខែចាប់តាំងពីអ្នកបើកបរ រហូតដល់ព្រះរាជអាជ្ញា ចៅក្រម គិតចាប់ពីខែធ្នូ ឆ្នាំ២០១២ នេះតទៅ។

ឯកឧត្តម ក្រាញ់ តូនី បានកោតសរសើរលើកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលិកទាំងអស់ ដែលបានបំពេញការងារបានយ៉ាងល្អ ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ នៅក្នុងដំណើរការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២ ដែលរហូតមកទល់ពេលនេះដំណើរការបានចំនួន ១៤២ ថ្ងៃ ដោយបានស្តាប់ការផ្តល់សក្ខីកម្មលើសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីប្រមាណ ៥០ រូប។ ទន្ទឹមគ្នានេះ ឯកឧត្តម ក្រាញ់ តូនី បានជម្រាបជូនអំពីស្ថានភាពថវិការបស់សាលាក្តី និងបញ្ហាប្រឈមដែលជាកង្វល់ដ៏ធ្ងន់ធ្ងរមួយ គឺការខ្វះសាច់ប្រាក់សម្រាប់បើកប្រាក់ខែជូនបុគ្គលិកជាតិទាំងអស់។

ឯកឧត្តមបានជម្រាបអង្គប្រជុំថា៖

ទី១-ភាគីជាតិមានថវិកាសម្រាប់ដំណើរការដល់ចុងឆ្នាំ២០១២នេះ ប៉ុន្តែអាចនឹងជួបប្រទះនូវកង្វះសាច់ប្រាក់ ដើម្បីបើកប្រាក់ខែសម្រាប់ខែធ្នូនេះតែម្តង គឺមានការយឺតយ៉ាវប្រហែលពីពីរទៅបីសប្តាហ៍។ ផ្នែកថវិកា និងហិរញ្ញវត្ថុ កំពុងធ្វើការងារជាមួយម្ចាស់ជំនួយ និងអ្នកគ្រប់គ្រងថវិកា ដើម្បីទទួលបានថវិកាដែលនៅសល់ប្រមាណ ៣ សែនដុល្លារអាមេរិក ដែលស្ថិតនៅក្នុងគម្រោងគាំទ្រដោយសហភាពអឺរ៉ុប យកមកទូទាត់ប្រាក់បៀវត្សរ៍សម្រាប់ខែធ្នូ ឆ្នាំ ២០១២ នេះ។

ទី២- ចំពោះគម្រោងថវិកាឆ្នាំ២០១៣ ភាគីជាតិត្រូវការថវិកាចំនួន ៩,៥ លានដុល្លារអាមេរិក។ ខុសប្លែកពីឆ្នាំមុនៗ រហូតមកទល់ពេលនេះ មិនទាន់មានការសន្យាជាក់លាក់ណាមួយពីប្រទេសម្ចាស់ជំនួយដល់ភាគីជាតិនៃ អ.វ.ត.ក នៅឡើយទេ លើកលែងតែការសន្យាដែលមានរួចហើយចំនួន ២,៥លានដុល្លារអាមេរិក

ដែលក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាចំនួន ១,៨លានដុល្លារអាមេរិក និងរដ្ឋាភិបាលអាឡឺម៉ង់ចំនួន ៧ សែនដុល្លារអាមេរិក។

ជាមួយគ្នានោះដែរ ឯកឧត្តម ក្រាញ់ តូនី ក៏បានរំលឹកឡើងអំពីប្រភពថវិកាដែលផ្តល់ឲ្យ អ.វ.ត.ក គឺបានមកពីប្រភពពីរសំខាន់ៈ គឺថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា និងថវិកាស្ម័គ្រចិត្តពីប្រទេសជាមិត្ត របស់ អ.វ.ត.ក។ ចំពោះថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា គឺបានផ្តល់ឲ្យដោយទាន់ពេលវេលា និងមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ សម្រាប់ទ្រទ្រង់ដំណើរការសេវាមូលដ្ឋានទូទៅរបស់សាលាក្តីរួមមានៈ ថ្លៃទឹក-ភ្លើង ការជួសជុលនិងថែទាំអាគារ សេវាដឹកជញ្ជូនបុគ្គលិកជាតិ-អន្តរជាតិទាំងអស់ សេវាថែទាំសុខភាពរបស់ជនជាប់ចោទ និងការងារផ្សព្វផ្សាយរបស់តុលាការ។ រីឯប្រាក់ខែ សម្រាប់បុគ្គលិកជាតិទាំងអស់ គឺចំណុះទាំងស្រុងទៅលើថវិកាស្ម័គ្រចិត្តផ្តល់ ដោយប្រទេសជាមិត្តរបស់ អ.វ.ត.ក។ ប្រទេសម្ចាស់ជំនួយគន្លឹះដែលគាំទ្រភាគីជាតិរួមមានៈ ជប៉ុន សហភាពអឺរ៉ុប អូស្ត្រាលី អាឡឺម៉ង់ និងចក្រភពអង់គ្លេស។

ឯកឧត្តម ក្រាញ់ តូនី បានគូសបញ្ជាក់ថា សម្រាប់ឆ្នាំ ២០១៣ ខាងមុខ បុគ្គលិកទាំងអស់នឹងប្រឈមមុខនឹងការមិនទទួលបានប្រាក់ខែចាប់ពីខែមករា ឆ្នាំ២០១៣ តទៅ រហូតដល់មានការផ្តល់វិភាគទានថ្មីនាពេលខាងមុខ។ ជាថ្មីម្តងទៀត ការបំពេញការងារដោយគ្មានប្រាក់ខែ គឺពិតជាមានផលប៉ះពាល់ដល់ទឹកចិត្ត និងស្មារតីរបស់បុគ្គលិកជាតិទាំងអស់។ ក្នុងស្ថានភាពបែបនេះ ឯកឧត្តមសង្ឃឹមថាប្រទេសផ្តល់ជំនួយសំខាន់ៗរបស់ អ.វ.ត.ក នឹងអនុម័តគម្រោងថវិកាកែសម្រួលឆ្នាំ២០១៣ ឲ្យបានឆាប់ និង ផ្តល់ថវិកាសង្គ្រោះបន្ទាន់ (Bridging funds) ដើម្បីបន្តនិរន្តរភាពការងារតុលាការ និងចៀសវាងការរាំងស្ទះដល់ដំណើរការសវនាការជំនុំជម្រះក្តីដែលកំពុងអនុវត្តទៅដោយសកម្ម និងដោយរលូនល្អ៕